# ការរៀបចំទទួលស្គាល់គ្នាទៅវិញទៅមកសម្រាប់សេវាថែទាំ របស់អាស៊ាន ឆ្នាំ ២០០៦

## ចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ក្នុងទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៦

http://www.aseansec.org/19210.htm]


ប្រការ I គោលបំណង ... ៣

ប្រការ II និយមន័យ និងវិសាលភាព ... ៤

ប្រការ III ការទទួលស្គាល់ គុណវឌ្ឍិ និងលក្ខណៈសម្បត្តិសម្រាប់ទទួលស្គាល់គិលានុបដ្ឋាក/យិកាបរទេស ... ៦

- ៣.១ ការទទួលស្គាល់គិលានុបដ្ឋាក/យិការបរទេស ... ៦
- ៣.២ លក្ខណៈសម្បត្តិសម្រាប់ទទួលស្គាល់គិលានុបដ្ឋាក/យិកាបរទេស ... ៧
- ៣.៣ ការប្រកបវិជ្ជាជីវៈរបស់គិលានុបដ្ឋាក/យិកាបរទេស ... ៧

ប្រការ IV ការវាយតម្លៃ ការចុះបញ្ជី និងការពិនិត្យតាមដាន ... ៨

- ៤.១ អាជ្ញាធរនិយ័តកម្មខាងសេវាថែទាំ ... ៨
- ៤.២ គណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានខាងសេវាថែទាំ ... ៩

ប្រការ V ការលើកលែងឲ្យគ្នាទៅវិញទៅមក ... ១០

- ៥.១ ការលើកលែងឲ្យគ្នាទៅវិញទៅមក ... ១០

ប្រការ VI ការដោះស្រាយវិវាទ ... ១០

ប្រការ VII ការអនុវត្តប្បញ្ញត្តិនៃ GATS និង AFAS ចំពោះ កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ ... ១១

ប្រការ VIII ការធ្វើវិសោធនកម្ម ... ១២

ប្រការ IX ការពន្យាពេលការអនុវត្ត ... ១២

ប្រការ X អវសានប្បញ្ញត្តិ ... ១៣


ការបកប្រែក្រៅផ្លូវការ

## បុព្វកថា

រដ្ឋាភិបាលប្រទេសប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាប្រទេសសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ជាផ្លូវការត្រូវបានហៅរួមគ្នាថា "អាស៊ាន" ឬ "បណ្តាប្រទេសជាសមាជិកអាស៊ាន" ឬ ហៅមួយៗថា "ប្រទេសជាសមាជិកអាស៊ាន"។

ដោយទទួលស្គាល់ពីគោលបំណងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌរបស់អាស៊ានស្តីពី សេវាកម្ម (ជាផ្លូវការហៅកាត់ថា "AFAS") ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការខាងការផ្តល់សេវាកម្មក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ានសំដៅបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ធ្វើពិពិធកម្មសមត្ថភាពផលិតកម្ម និងការផ្គត់ផ្គង់ និងការបែងចែកសេវាកម្ម របស់អ្នកផ្គត់ផ្គង់សេវា ទាំងខាងក្នុង និងខាងក្រៅអាស៊ាន ដើម្បីលុបបំបាត់ឲ្យបានច្រើននូវការរឹតបន្តឹងខាងពាណិជ្ជកម្មលើសេវាកម្មក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន និងដើម្បីធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មលើសេវាកម្មតាមរយៈការពង្រីកវិសាលភាព និងភាពស៊ីជម្រៅនៃការធ្វើសេរីភាវូបនីយកម្មនេះ លើសពីអ្វីដែលបានអនុវត្តដោយបណ្តាប្រទេសជាសមាជិកអាស៊ាន ក្រោមកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មលើសេវាកម្ម (ជាផ្លូវការហៅថា "GATS") ក្នុងគោលបំណងសម្រេចអោយបាននូវពាណិជ្ជកម្មដោយសេរីលើសេវាកម្ម។

ដោយទទួលស្គាល់ចក្ខុវិស័យអាស៊ាន ឆ្នាំ ២០២០ ស្តីពីភាពជាដៃគូក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ដែលបានអនុម័តនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៧ ដែលទិសដៅឆ្ពោះទៅឆ្នាំ ២០២០ ដើម្បីឲ្យអាស៊ានអាចបង្កើតបាននូវតំបន់សេដ្ឋកិច្ចអាស៊ានប្រកបដោយស្ថិរភាព វិបុលភាព និងមានភាពប្រកួតប្រជែងខ្ពស់ដែលនាំឲ្យមាននះ លំហូរដោយសេរីនូវទំនិញ សេវាកម្ម និងការវិនិយោគ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និងការកាត់បន្ថយភាពក្រីក្រ និងគម្លា-តខាងសេដ្ឋកិច្ចសង្គម និងការលើកកម្ពស់ស្ថិរភាពនយោបាយសេដ្ឋកិច្ច និងសង្គម។

**ដោយកត់សម្គាល់ថា** ប្រការ V នៃ AFAS ចែងថាប្រទេសជាសមាជិកអាស៊ានអាចទទួលស្គាល់ការអប់រំ ឬបទពិសោធន៍ដែលទទួលបាន, លក្ខខណ្ឌតម្រូវដែលបានបំពេញ និងអាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រដែលត្រូវបានផ្តល់ក្នុងប្រទេសជាសមាជិកអាស៊ានផ្សេងទៀត ក្នុងគោលបំណងនៃការចេញអាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ដល់អ្នកផ្តល់សេវា។

**ដោយកត់សម្គាល់ថា** សេចក្តីសម្រេចនៃកិច្ចព្រមព្រៀង Bali Concord II ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៩ ក្នុងឆ្នាំ២០០៣ ដែលអំពាវនាវឲ្យមានការរៀបចំកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក (ជាផ្លូវការហៅថា "MRAs" ជាពហុវចនៈ និង "MRA" ជាឯកវចនៈ) ដល់គុណវឌ្ឍិ លើសេវាវិជ្ជាជីវៈសំខាន់ៗត្រឹមឆ្នាំ ២០០៨ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការចល័តនូវអ្នកជំនាញ/ពលករជំនាញ/អ្នកដែលមានទេពកោសល្យដោយសេរីក្នុងអាស៊ាន និង

**ការផ្តល់នូវ**កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកលើសេវាថៃទាំ (MRA on Nursing Services) ដែលនឹងពង្រឹងសមត្ថភាពវិជ្ជាជីវៈ តាមរយៈការជម្រុញឲ្យមានលំហូរព័ត៌មានពាក់ព័ន្ធ ក៏ដូចជាការផ្លោះប្តូរជំនាញ បទពិសោធន៍ និងការអនុវត្តល្អៗ សមស្របទៅនឹងតម្រូវការជាក់លាក់របស់ប្រទេសជាសមាជិកអាស៊ាន។

**បានឯកភាពគ្នា**ដូចខាងក្រោម៖

## ប្រការ I
## គោលបំណង

គោលបំណងនៃកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះរួមមាន៖

១.១ សម្របសម្រួលចល័តភាពរបស់អ្នកជំនាញប្រកបដោយវិជ្ជាជីវៈលើការផ្តល់សេវាថៃទាំក្នុងអាស៊ាន

១.២ ផ្លោះប្តូរព័ត៌មាន និងជំនាញឯកទេសលើស្តង់ដា និងគុណវឌ្ឍិ

១.៣ ជម្រុញឲ្យមានការទទួលយកការអនុវត្តល្អៗលើសេវាថៃទាំប្រកបដោយវិជ្ជាជីវៈ និង

១.៤ ផ្តល់ឱកាសឲ្យមានការកសាងសមត្ថភាព និងការបណ្តុះបណ្តាលដល់គិលានុបដ្ឋាក/យិកា

## ប្រការ II
## និយមន័យ និងវិសាលភាព

លើកលែងតែមានការចែងបរិបទផ្សេងទៀត នៅក្នុងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ៖

២.១ ពាក្យថា **គិលានុបដ្ឋាក/យិកា** សំដៅលើរូបវន្តបុគ្គល ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ



ការបកប្រែក្រៅផ្លូវការ

វិជ្ជាជីវៈដែលចាំបាច់ត្រូវមាន និងទទួលបានគុណវឌ្ឍិជំនាញលើការផ្តល់សេវាថែទាំ និងត្រូវបានវាយតម្លៃពីអាជ្ញាធរនិយ័តកម្មលើជំនាញថែទាំនៃប្រទេសសាមី៉ ថាមានសមត្ថភាពបច្ចេកទេសប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងច្បាប់ដើម្បីអនុវត្តការងារថែទាំប្រកបដោយវិជ្ជាជីវៈ និងបានចុះបញ្ជិកា និង/ឬទទួលបានអាជ្ញាប័ណ្ណជាគិលានុបដ្ឋាក/យិកាជំនាញ ដោយអាជ្ញាធរនិយ័តកម្មលើជំនាញថែទាំ នៃប្រទេសសាមី៉។ និយមន័យនេះមិនត្រូវអនុវត្តចំពោះគិលានុបដ្ឋាក/យិកាកម្រិតបច្ចេកទេសឡើយ។

២.២ **ប្រទេសសាមី៉** សំដៅលើប្រទេសជាសមាជិកអាស៊ាន ដែលគិលានុបដ្ឋាក/យិកាបានទទួលការចុះបញ្ជិកា និង/ឬអាជ្ញាប័ណ្ណដែលមានសុពលភាពអនុវត្តការថែទាំ។

២.៣ **គិលានុបដ្ឋាក/យិកាបរទេស** សំដៅលើគិលានុបដ្ឋាក/យិកា ដែលមានសញ្ជាតិក្នុងប្រទេសណាមួយនៃប្រទេសសមាជិកអាស៊ាន ដែលបានទទួលការចុះបញ្ជិកា និង/ឬអាជ្ញាប័ណ្ណ ដើម្បីប្រកបវិជ្ជាជីវៈជាគិលានុបដ្ឋាក/យិកាក្នុងប្រទេសសាមី៉ និងកំពុងដាក់ពាក្យសុំចុះបញ្ជិកា និង/ឬអាជ្ញាប័ណ្ណ ដើម្បីប្រកបវិជ្ជាជីវៈជាគិលានុបដ្ឋាក/យិកាក្នុងប្រទេសម្ចាស់ផ្ទះ ស្របតាមគោលនយោបាយស្តីពីការប្រកបវិជ្ជាជីវៈជាគិលានុបដ្ឋាក/យិកាក្នុងប្រទេសម្ចាស់ផ្ទះ។

២.៤ **ប្រទេសម្ចាស់ផ្ទះ** សំដៅលើប្រទេសជាសមាជិកអាស៊ានដែលគិលានុបដ្ឋាក/យិកាបរទេសដាក់ពាក្យសុំចុះបញ្ជិកា និង/ឬអាជ្ញាប័ណ្ណ ដើម្បីប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា។

២.៥ **គុណវឌ្ឍិជំនាញលើការថែទាំ** មានន័យថាគុណវឌ្ឍិជំនាញលើការថែទាំដែលផ្តល់ដោយគ្រឹះស្ថានបណ្តុះបណ្តាល ដែលទទួលបានការឯកភាព និងទទួលស្គាល់ពីអាជ្ញាធរនិយ័តកម្មលើសេវាថែទាំ និង/ឬទីភ្នាក់ងារសមស្របរបស់ប្រទេសសាមី៉។

២.៦ **អាជ្ញាធរនិយ័តកម្មលើសេវាថែទាំ** (ដែលជាផ្លូវការហៅកាត់ថា "NRA") សំដៅលើស្ថាប័នដែលពិភាក្សាជាមួយអាជ្ញាធរដោយរដ្ឋាភិបាលនៃប្រទេសជាសមាជិកអាស៊ាននីមួយៗដើម្បីគ្រប់គ្រង និងធ្វើនិយ័តកម្មលើគិលានុបដ្ឋាក/យិកា និងការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា។ ក្នុងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់គ្នាទៅវិញទៅមកនេះ NRA សំដៅលើស្ថាប័នដូចខាងក្រោមៈ

| | |
|---|---|
| ក្រុមប្រឹក្សាភិបាលគិលានុបដ្ឋាក/យិកានៃប្រទេសប្រ៊ុយណេ | សម្រាប់ប្រទេសប្រ៊ុយណេដារូសាឡឹម |

| | |
|---|---|
| ក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា | សម្រាប់ព្រះរាជាណាចក្រកម្ពុជា |
| ក្រសួងសុខាភិបាល នៃសាធារណរដ្ឋឥណ្ឌូនេស៊ី | សម្រាប់សាធារណរដ្ឋឥណ្ឌូនេស៊ី |
| ក្រសួងសុខាភិបាល នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ | សម្រាប់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ |
| ក្រុមប្រឹក្សាភិបាលសុខាភិបាល និងឆ្មប នៃប្រទេសម៉ាឡេស៊ី | សម្រាប់ប្រទេសម៉ាឡេស៊ី |
| ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាភិបាលគិលានុបដ្ឋាក/យិកា និងឆ្មប នៃប្រទេសមីយ៉ាន់ម៉ា | សម្រាប់សហភាពមីយ៉ាន់ម៉ា |
| គណៈកម្មការនិយ័តកម្មវិជ្ជាជីវៈ ក្រុមប្រឹក្សាភិបាលនៃគិលានុបដ្ឋាក/យិកា | សម្រាប់សាធារណរដ្ឋហ្វីលីពីន |
| ក្រុមប្រឹក្សាភិបាលនៃគិលានុបដ្ឋាក/យិកានៃប្រទេសសឹង្ហបុរី | សម្រាប់សាធារណរដ្ឋសឹង្ហបុរី |
| ក្រុមប្រឹក្សាភិបាលនៃគិលានុបដ្ឋាក/យិការបស់ប្រទេសថៃ | សម្រាប់ព្រះរាជាណាចក្រថៃ |
| ក្រសួងសុខាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម | សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម |

ការបកប្រែក្រៅផ្លូវការ

២.៧ **ការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា** សំដៅលើការផ្តល់សេវាថែទាំ ដោយគិលានុបដ្ឋាក/យិកា ដែលគ្របដណ្តប់លើការផ្តល់សេវាលើកកម្ពស់ បង្ការ ការព្យាបាល និងស្តារលទ្ធភាពពលកម្ម ដែលអាចរាប់បញ្ចូលទាំងការអប់រំ និងការស្រាវជ្រាវផងដែរ។

២.៨ **ស្ថាប័នបណ្តុះបណ្តាលដែលមានការទទួលស្គាល់** សំដៅលើសកលវិទ្យាល័យ មហាវិទ្យាល័យ ឬគ្រឹះស្ថានអប់រំខាងជំនាញថែទាំ ដែលទទួលបានការឯកភាពពីអាជ្ញាធរនិយ័តកម្មលើសេវាថែទាំ និង

/ឬទីភ្នាក់ងារសមស្របនៃប្រទេសសាមី៊ ដោយអនុវត្តតាមនីតិវិធី ដែលបានដាក់ចេញដោយរដ្ឋាភិបាល ឬអាជ្ញាធរពាក់ព័ន្ធរបស់ប្រទេសសាមី៊។

## ប្រការ III
## ការទទួលស្គាល់ គុណវឌ្ឍិ និងលក្ខណៈសម្បត្តិសម្រាប់ទទួលស្គាល់គិលានុបដ្ឋាក/យិកាបរទេស

### ៣.១ ការទទួលស្គាល់គិលានុបដ្ឋាក/យិកាបរទេស

គិលានុបដ្ឋាក/យិកាបរទេសអាចដាក់ពាក្យសុំចុះបញ្ជី ឬអាជ្ញាប័ណ្ណក្នុងប្រទេសម្ចាស់ផ្ទះ ដើម្បីទទួលបានការទទួលស្គាល់ និងការអនុញ្ញាតឲ្យប្រកបវិជ្ជាជីវៈផ្តល់សេវាថែទាំស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃប្រទេសម្ចាស់ផ្ទះទៅតាមលក្ខខណ្ឌខាងក្រោម៖

៣.១.១ បានទទួលគុណវឌ្ឍិដើម្បីប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា។

៣.១.២ មានបញ្ជិកាវិជ្ជាជីវៈ និង/ឬអាជ្ញាប័ណ្ណមានសុពលភាពពីប្រទេសសាមី៊ និងអាជ្ញាប័ណ្ណ ឬវិញ្ញាបនបត្រប្រកបវិជ្ជាជីវៈដែលនៅមានសុពលភាពនៅឡើយ ឬឯកសារបញ្ជាក់ពាក់ព័ន្ធផ្សេងទៀត។

៣.១.៣ បទពិសោធន៍អប្បរមាខាងការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកាមិនក្រោមបី (៣) ឆ្នាំ ជាប់គ្នាមុនពេលដាក់ពាក្យសុំនេះ។

៣.១.៤ ការអនុវត្តតាមការអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្តក្នុងកម្រិតពេញចិត្ត ស្របតាមគោលនយោបាយស្តីពីការអភិវឌ្ឍន៍វិជ្ជាជីវៈបន្តលើគិលានុបដ្ឋាក/យិកា ដែលអាចតម្រូវដោយ NRA នៃប្រទេសសាមី៊។

៣.១.៥ ការផ្តល់វិញ្ញាបនបត្រដោយ NRA នៃប្រទេសសាមី៊ដោយពុំមានកំណាត់ត្រាបង្ហាញ ឬកំពុងរង់ចាំការស៊ើបអង្កេតដែលបំពានស្តង់ដាបច្ចេកទេស វិជ្ជាជីវៈ ឬក្រមសីលធម៌វិជ្ជាជីវៈទាំងក្នុងប្រទេស ទាំងក្រៅប្រទេស សម្រាប់ការអនុវត្តវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា។

៣.១.៦ ការអនុវត្តតាមលក្ខខណ្ឌតម្រូវដទៃទៀត ដូចជាត្រូវឆ្លងកាត់ការពិនិត្យសុខភាពផ្ទាល់ខ្លួន ឬឆ្លងកាត់កម្មវិធីណែនាំដំបូង ឬការវាយតម្លៃសមត្ថភាពណាមួយដែលអាចត្រូវបានដាក់ជាលក្ខខណ្ឌសម្រាប់ការដាក់ពាក្យសុំចុះបញ្ជិកា និង/ឬអាជ្ញាប័ណ្ណ ដែល NRA ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត


ការបកប្រែក្រៅផ្លូវការ

ឬរដ្ឋាភិបាលរបស់ប្រទេសម្ចាស់ផ្ទះដែលពាក់ព័ន្ធ។

### ៣.២ លក្ខណៈសម្បត្តិសម្រាប់ទទួលស្គាល់គិលានុបដ្ឋាក/យិកាបរទេស

អាស្រ័យលើច្បាប់ និងលិខិតបទដ្ឋានក្នុងប្រទេស គិលានុបដ្ឋាក/យិកាបរទេស ដែលពេញចិត្ត តាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៣.១ ត្រូវបានចាត់ទុកថាមានលក្ខណៈសម្បត្តិសមស្រប ដើម្បីធ្វើការងារក្នុងប្រទេសម្ចាស់ផ្ទះ។

### ៣.៣ ការប្រកបវិជ្ជាជីវៈរបស់គិលានុបដ្ឋាក/យិកាបរទេស

គិលានុបដ្ឋាក/យិកាបរទេស ដែលបានទទួលការចុះបញ្ជី ឬអាជ្ញាប័ណ្ណក្នុងប្រទេសម្ចាស់ផ្ទះ ដើម្បីប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា ត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោមៈ

៣.៣.១ ក្រមសីលធម៌វិជ្ជាជីវៈក្នុងប្រទេស ចែងស្របទៅតាមគោលនយោបាយស្តីពីក្រមសីលធម៌ សម្រាប់ការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកាដែលត្រូវបានដាក់ចេញ និងអនុវត្តដោយប្រទេសម្ចាស់ផ្ទះ។

៣.៣.២ ច្បាប់ និងលិខិតបទដ្ឋាន ដែលមានស្រាប់ក្នុងប្រទេសម្ចាស់ផ្ទះ រួមមានវិធាន និងលិខិតបទដ្ឋានគតិយុត្តិ ដែលគ្របដណ្តប់លើការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកាក្នុងប្រទេសម្ចាស់ផ្ទះ។

៣.៣.៣ ទិញគម្រោងធានារ៉ាប់រង (insurance liability scheme) ដែលតម្រូវដោយប្រទេសម្ចាស់ផ្ទះ។ និង

៣.៣.៤ គោរពវប្បធម៌ និងសាសនារបស់ប្រទេសម្ចាស់ផ្ទះ។

## ប្រការ IV
## ការវាយតម្លៃ ការចុះបញ្ជី និងការពិនិត្យតាមដាន

### ៤.១ អាជ្ញាធរនិយ័តកម្មខាងសេវាថែទាំ (NRA)

NRA របស់ប្រទេសជាម្ចាស់ផ្ទះត្រូវទទួលខុសត្រូវលើសកម្មភាពដូចខាងក្រោមៈ



ការបកប្រែក្រៅផ្លូវការ

៤.១.១ វាយតម្លៃលើគុណវឌ្ឍិ និងបទពិសោធន៍របស់គិលានុបដ្ឋាក/យិកាបរទេស

៤.១.២ ចុះបញ្ជី និង/ឬផ្តល់អាជ្ញាប័ណ្ណដល់គិលានុបដ្ឋាក/យិកាបរទេស ដើម្បីប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា ក្នុងប្រទេសម្ចាស់ផ្ទះ

៤.១.៣ ពិនិត្យតាមដានការប្រកបវិជ្ជាជីវៈ និងការអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈរបស់គិលានុបដ្ឋាក/យិកាបរទេស ដែលបានចុះបញ្ជី និង/ឬទទួលបានអាជ្ញាប័ណ្ណ និង

៤.១.៤ ធានាថាគិលានុបដ្ឋាក/យិកាបរទេសសង្កេត និងរក្សាការអនុវត្តតាមស្តង់ដាកម្រិតខ្ពស់នៃវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា ស្របតាមក្រមសីលធម៌វិជ្ជាជីវៈរបស់ប្រទេសម្ចាស់ផ្ទះ។

**៤.២ គណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានលើសេវាថៃទាំ**

៤.២.១ គណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានលើសេវាថៃទាំនឹងត្រូវបានបង្កើតឡើងដោយមានសមាសភាពជាតំណាងមកពី NRA និង/ឬទីភ្នាក់ងាររដ្ឋាភិបាលសមស្របនៃប្រទេសដែលចូលរួមជាសមាជិកអាស៊ានដើម្បីជួបប្រជុំគ្នាជាទៀងទាត់ដើម្បី៖

៤.២.១.១ សម្របសម្រួលការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ។

៤.២.១.២ ខិតខំធ្វើការស្វែងយល់បន្ថែមទៀតពីគោលនយោបាយ នីតិវិធី និងការអនុវត្តដែលមានស្រាប់ដើម្បីបង្កើត និងលើកកម្ពស់យុទ្ធសាស្ត្រ ដើម្បីគ្រប់គ្រងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ។

៤.២.១.៣ លើកទឹកចិត្តឲ្យមានការអនុវត្ត និងការធ្វើសុខុដុមនីយកម្មស្តង់ដា និងនីតិវិធីនានាក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះតាមរយៈយន្តការដែលមាន។

៤.២.១.៤ ធ្វើបច្ចុប្បន្នភាពពីការផ្លាស់ប្តូរ ឬការអភិវឌ្ឍនានាខាងច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងការអនុវត្តដែលមានស្រាប់នៅក្នុងប្រទេសម្ចាស់ផ្ទះនីមួយៗ។

៤.២.១.៥ បន្តធ្វើការពិនិត្យតាមដាន និងផ្លោះប្តូរព័ត៌មានឲ្យគ្នាទៅវិញទៅមក។

៤.២.១.៦ ផ្តល់ជាផ្លូវដើម្បីដោះស្រាយនូវជម្លោះ ឬវិវាទនានា ដែលកើតឡើងលើការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកដោយសន្តិវិធី ដែលត្រូវបានបញ្ជូនមកដោយ NRA របស់

ប្រទេសដែលចូលជាសមាជិកអាស៊ាន។

៤.២.១.៧ ពិភាក្សាពីការរៀបចំកម្មវិធីកសាងសមត្ថភាព និង

៤.២.១.៨ ពិភាក្សាពីបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធជាមួយនឹងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ។

៤.២.២ គណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានលើសេវាថែទាំ ត្រូវបង្កើតយន្តការដើម្បីអនុវត្តអាណត្តិរបស់ខ្លួន។

## ប្រការ V
## ការលើកលែងឲ្យគ្នាទៅវិញទៅមក

### ៥.១ ការលើកលែងឲ្យគ្នាទៅវិញទៅមក

៥.១.១ ប្រទេសដែលជាសមាជិកអាស៊ានទទួលស្គាល់ថាការរៀបចំទាំងឡាយ ដែលបានផ្តល់ការលើកលែងពីការវាយតម្លៃបន្ថែមដោយ NRA នៃប្រទេសម្ចាស់ផ្ទះអាចធ្វើទៅបានដោយមានតែការចូលរួម និងការយល់ព្រមពី NRA និង/ឬទីភ្នាក់ងារពាក់ព័ន្ធរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ។

៥.១.២ ប្រទេសជាសមាជិកអាស៊ានទទួលស្គាល់បន្ថែមទៀតផងដែរថា អាជ្ញាធរចុះបញ្ជី ឬអាជ្ញាធរចេញអាជ្ញាប័ណ្ណសម្រាប់ការប្រកបវិជ្ជាជីវៈគិលានុបដ្ឋាក/យិកា មានការទទួលខុសត្រូវកំណត់ដោយច្បាប់ លើការការពារសុខភាព សុវត្ថិភាព បរិស្ថាន និងសុខុមាលភាពរបស់សហគមន៍ក្នុងយុត្តាធិការរបស់ខ្លួន។

## ប្រការ VI
## ការដោះស្រាយវិវាទ

៦.១ គណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានលើសេវាថែទាំ នឹងសង្កេតលើយន្តការខាងក្រោម ដើម្បីដោះស្រាយវិវាទដែលកើតឡើងចេញពីការបកស្រាយ ការអនុវត្ត និង/ឬការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ៖

៦.១.១ គិលានុបដ្ឋាក/យិកាបរទេសអាចដាក់ពាក្យបណ្តឹងដែលកើតចេញពីកិច្ចព្រមព្រៀងស្តីពីការ



ការបកប្រែក្រៅផ្លូវការ

ទទួលស្គាល់ទៅវិញទៅមកនេះទៅកាន់ NRA របស់ប្រទេសម្ចាស់ផ្ទះ។

៦.១.២ ប្រសិនបើគិលានុបដ្ឋាយិកាបរទេសមិនពេញចិត្តនឹងវិធានការ ឬការពន្យល់របស់ NRA របស់ប្រទេសម្ចាស់ផ្ទះដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង នោះគិលានុបដ្ឋាក/យិកាបរទេសអាចទាក់ទងទៅកាន់ NRA របស់ប្រទេសសាមី ដើម្បីធ្វើការពិគ្រោះយោបលជាមួយនឹង NRA របស់ប្រទេសម្ចាស់ផ្ទះដើម្បីដោះស្រាយវិវាទនេះ។

៦.១.៣ NRA របស់ប្រទេសសាមី ឬប្រទេសម្ចាស់ផ្ទះ ត្រូវផ្ញើវិវាទដែលមិនទាន់បានដោះស្រាយរួចពីការពិគ្រោះយោបល់ទាំងឡាយទៅកាន់គណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានលើសេវាថៃទាំដែលត្រូវខិតខំដោះស្រាយវិវាទនេះដោយសន្តិវិធី និង

៦.១.៤ វិវាទដែលពាក់ព័ន្ធជាមួយនឹងការបកស្រាយ ការអនុវត្ត និង/ឬការអនុវត្តប្បញ្ញត្តិណាមួយក្រោមកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ ដែលមិនអាចដោះស្រាយបានដោយគណៈកម្មាធិការសម្របសម្រួលចម្រុះរបស់អាស៊ានលើសេវាថៃទាំ ត្រូវដោះស្រាយដោយប្រើប្រាស់យន្តការដែលត្រូវបានដាក់ចេញក្នុងពិធីសារអាស៊ានស្តីពីការលើកកម្ពស់យន្តការដោះស្រាយវិវាទដែលបានដាក់ចេញក្នុងទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៤។

## ប្រការ VII
## ការអនុវត្តប្បញ្ញត្តិនៃ GATS និង AFAS លើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ

វាក្យស័ព្ទ និងនិយមន័យ និងប្បញ្ញត្តិផ្សេងទៀតនៃ GATS និង AFAS ត្រូវយោងតាម និងត្រូវអនុវត្តចំពោះបញ្ហានានា ដែលកើតចេញពីកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះក្នុងករណីដែលកិច្ចព្រមព្រៀងនេះពុំបានលើកឡើងពីប្បញ្ញត្តិជាក់លាក់។

## ប្រការ VIII
## ការធ្វើវិសោធនកម្ម

ការបកប្រែក្រៅផ្លូវការ

ប្បញ្ញត្តិនានាក្នុងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ អាចធ្វើវិសោធនកម្មបាន តែដោយមានកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សររវាងគ្នាទៅវិញទៅមកដោយរដ្ឋាភិបាលរបស់ប្រទេសជាសមាជិកអាស៊ានទាំងអស់ប៉ុណ្ណោះ។

## **ប្រការ IX**
## **ការពន្យាពេលការអនុវត្ត**

៩.១ ប្រទេសជាសមាជិកអាស៊ានទាំងឡាយ ដែលមានបំណងពន្យាពេលអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ ត្រូវជូនដំណឹងជាលាយល័ក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការអាស៊ានជាលាយល័ក្ខណ៍អក្សរពីបំណងរបស់ខ្លួន មិនឲ្យហួសពីបីខែ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ហើយអគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងដល់ប្រទេសជាសមាជិកអាស៊ានដទៃទៀត។ ការពន្យាពេលនេះនឹងចូលជាធរមាន ក្រោយពីមានការជូនដំណឹងដល់ប្រទេសជាសមាជិកអាស៊ានដទៃទៀត។ ប្រទេសជាសមាជិកអាស៊ានដែលមិនពន្យាពេលអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះត្រូវបានហៅថា "ប្រទេសជាសមាជិកអាស៊ានដែលចូលរួម" ក្នុងកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ។

៩.២ ប្រទេសជាសមាជិកអាស៊ានដែលបានជូនដំណឹងពីបំណងពន្យាពេលការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ ស្របតាមប្រការ ៩.១ ខាងលើ ត្រូវជូនដំណឹងដល់អគ្គលេខាធិការអាស៊ានជាលាយល័ក្ខណ៍អក្សរពីពេលដែលខ្លួនត្រៀមខ្លួនរួចរាល់ ក្នុងការអនុវត្តកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះ ដរាបណាកាលបរិច្ឆេទនេះមិនហួសពីថ្ងៃទី ១ ខែមករា ឆ្នាំ ២០១០។ អគ្គលេខាធិការអាស៊ានត្រូវជូនដំណឹងនេះដល់ប្រទេសជាសមាជិកអាស៊ានដទៃទៀត។

## **ប្រការ X**
## **អវសានប្បញ្ញត្តិ**

១០.១ កិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់ទៅវិញទៅមកនេះត្រូវចូលជាធរមាន សម្រាប់គ្រប់ប្រទេសជាសមាជិកទាំងអស់នូវកាលបរិច្ឆេទនៃការចុះហត្ថលេខា។

១០.២ កិច្ចព្រមព្រៀងស្ដីពីការទទួលស្គាល់ទៅវិញទៅមកនេះត្រូវតម្កល់នៅអគ្គលេខាធិការអាស៊ាន ដែលត្រូវផ្ញើសំណៅចម្លងដែលមានការបញ្ជាក់ត្រឹមត្រូវជាបន្ទាន់ ទៅកាន់ប្រទេសជាសមាជិកអាស៊ាន នីមួយៗ។

**នៅចំពោះមុខសាក្សី** អ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលការអនុញ្ញាតត្រឹមត្រូវពីរដ្ឋាភិបាល របស់ពួកគេ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្ដីពីការរៀបចំការទទួលស្គាល់ទៅវិញទៅមករបស់ អាស៊ានលើសេវាថៃទាំនេះ។

**ធ្វើនៅ**ទីក្រុងសេប៊ូ ប្រទេសហ្វីលីពីន នៅថ្ងៃទីប្រាំបី ខែធ្នូ ឆ្នាំពីរពាន់ប្រាំមួយ លើឯកសារច្បាប់ដើមតែ មួយជាភាសាអង់គ្លេស។

តំណាងឲ្យប្រទេសប្រ៊ុយណេដារូសាឡឹម៖

MOHAMED BOLKIAH

រដ្ឋមន្ត្រីក្រសួងការបរទេស និងពាណិជ្ជកម្ម

តំណាងឲ្យព្រះរាជាណាចក្រកម្ពុជា៖

CHAM PRASIDH

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងឲ្យសាធារណរដ្ឋឥណ្ឌូនេស៊ី៖

MARI ELKA PANGESTU

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងឲ្យសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ៖

NAM VIYAKETH

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម

តំណាងឲ្យប្រទេសម៉ាឡេស៊ី៖



ការបកប្រែក្រៅផ្លូវការ

RAFIDAH AZIZ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មអន្តរជាតិ

តំណាងឲ្យសហភាពមីយ៉ាន់ម៉ា៖

U SOE THA

រដ្ឋមន្ត្រីក្រសួងផែនការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

តំណាងឲ្យសាធារណរដ្ឋហ្វីលីពីន៖

PETER B. FAVILA

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

តំណាងឲ្យសាធារណរដ្ឋសឹង្ហបុរី៖

LIM HNG KIANG

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម

តំណាងឲ្យព្រះរាជាណាចក្រថៃ៖

KRIRK-KRAI JIRAPAET

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

តំណាងឲ្យសាធារណរដ្ឋសង្គមនិយមវៀតណាម៖

TRUONG DINH TUYEN

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ការបកប្រែក្រៅផ្លូវការ